ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:..................អសជ/.....

# របាយការណ៍សង្ខេបនៃ
# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ
# ស្ដីពី
# ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
# កម្រិតរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុក នៃខេត្តកោះកុង

## ការិយបរិច្ឆេទ២០២៣

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA

Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900

E-mail: naakh@naa.gov.kh website: www.naa.gov.kh

**របាយការណ៍សង្ខេប**

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានជ្រើសរើសយកខេត្តកោះកុងសម្រាប់ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កម្រិតរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុក នៃខេត្តកោះកុង សម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ ដោយសារតែខេត្តកោះកុង ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់ជាប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយ អនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាញយកផលចំណូលពីទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន តាមគោលការណ៍ និងនីតិវិធីនៃការបែកចែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយសារកត្តានេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើអនុប្បយោគផ្ទៃដីទំហំ **១៥០ ០២០,៣៩**ហិកតា ជូនរដ្ឋបាលខេត្តកោះកុង ទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋកាន់កាប់ដោយរដ្ឋបាលខេត្តកោះកុង។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានធ្វើអនុប្បយោគដី និងកោះមួយចំនួនក្នុងភូមិសាស្ត្រនៃខេត្តកោះកុងសម្រាប់ជួលរយៈពេលវែងជូនក្រុមហ៊ុនវិនិយោគនានា ក្នុងនោះមាន កោះតាទឹម កោះទទឹង កោះស្មាច់ កោះដំឡូងក្នុង កោះដំឡូងក្រៅ ប្រជុំកោះអំពិល "កោះអំពិលក្នុង កោះអំពិលកណ្តាល និងកោះអំពិលក្រៅ" កោះម្នាស់ប៉ែកខាងត្បូងនិងកោះម្នាស់ប៉ែកខាងជើង ព្រមទាំងដីគោកមួយចំនួនទៀត។

ការធ្វើសវនកម្ម គឺដើម្បីវាយតម្លៃថា តើរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង អាចធានាបាននូវការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការកាន់កាប់ និងការប្រើប្រាស់របស់ខ្លួនដែរ ឬទេ។ ការធ្វើសវនកម្មនេះ បានផ្តោតជាសំខាន់លើ (១) ការចុះបញ្ជីដំបូងនូវអចលនទ្រព្យដែលបានកត់ត្រាក្នុងបញ្ជីសារពើភណ្ឌ និងដីដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើអនុប្បយោគ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលបានកាន់កាប់ដោយរដ្ឋបាលខេត្ត (២) ការកត់ត្រាដីដែលស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (៣) ការរក្សាទុកនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុទាំងអស់ ដែលបានកាន់កាប់ដោយរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង និង (៤) ការប្រើប្រាស់ ការចាត់ចែង និងការបែងចែកនូវទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ព្រមទាំងការថែរក្សា ការការពារ និងការអភិរក្ស ឱ្យបានគង់វង្សនូវទ្រព្យសម្បត្តិរដ្ឋដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ប្រកបដោយចីរភាព។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កម្រិតរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង សម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ ដែលស្ថិតនៅក្រោមការកាន់កាប់ និងការប្រើប្រាស់របស់រដ្ឋបាលខេត្តកោះកុង រដ្ឋបាលក្រុងខេមរភូមិន្ទ រដ្ឋបាលស្រុកកោះកុង រដ្ឋបាលស្រុកមណ្ឌលសីមា រដ្ឋបាលស្រុកបូទុមសាគរ រដ្ឋបាលស្រុកស្រែអំបិល និងរដ្ឋបាលស្រុកថ្មបាំង។

តាមរយៈការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កម្រិតរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង សម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិសូមបង្ហាញជូននូវលទ្ធផលសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

**១. កង្វះខាតក្នុងការចុះបញ្ជីដំបូងនៃទ្រព្យសម្បត្តិរដ្ឋ**

តាមគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតម្រូវឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋ ជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួន ឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកោះកុងមិនទាន់បានចុះបញ្ជីដំបូង ឬធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឱ្យបានគ្រប់ចំនួន ចំពោះដីធ្លីដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើអនុប្បយោគតាមអនុក្រឹត្យលេខ៣០អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ មានផ្ទៃដីទំហំ **១២៦ ៩២៨,៣៩**ហិកតា និងអនុក្រឹត្យលេខ៤៦អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ដែលមានផ្ទៃដីទំហំ**២៣ ០៩២**ហិកតា នៅក្នុងភូមិសាស្ត្រខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋមួយចំណែក និងមួយចំណែករក្សាទុក ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋកាន់កាប់ដោយរដ្ឋបាលខេត្តកោះកុងនៅឡើយ។

**២. កង្វះខាតក្នុងការកត់ត្រាអចលនវត្ថុមួយចំនួនចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ**

តាមគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋ។ ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបែបបទ និងនីតិវិធី ដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកោះកុង និងរដ្ឋបាលក្រុង-ស្រុកមួយចំនួនមិនទាន់កត់ត្រានូវអចលនវត្ថុមួយចំនួនដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅឡើយ បើទោះជាអចលនវត្ថុទាំងនោះ បានចុះបញ្ជីដីរដ្ឋ និងមិនទាន់បានចុះបញ្ជីក៏ដោយ ព្រមទាំងវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង និងបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនានា ក្នុងនោះ ៖

- រដ្ឋបាលខេត្តកោះកុងមានចំនួន១៧៣ប័ណ្ណ និងផ្ទៃដីមួយចំនួនទៀតអនុក្រឹត្យលេខ ៣០អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ មានទំហំ១២៦ ៩២៨,៣៩ហិកតា និង អនុក្រឹត្យលេខ៤៦អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ មានទំហំ២៣ ០៩២ ហិកតា។
- រដ្ឋបាលក្រុងខេមរភូមិន្ទ មានចំនួន០១ប័ណ្ណ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ០៩៤០៣០២-០៤២៦ មានទំហំ២៦ ៩៧០ម²
- រដ្ឋបាលស្រុកថ្មបាំង មានចំនួន០២ទីតាំង ក្នុងនោះមាន ទីតាំងផ្សារដីផាត មានទំហំ ៩០៥ម² និងទីតាំងដីសាលាស្រុកថ្មបាំងថ្មី មានទំហំ៩ ១០៩ម²
- រដ្ឋបាលស្រុកបូទុមសាគរ មានចំនួន០១ទីតាំង គឺផ្សារថ្មស
- រដ្ឋបាលស្រុកស្រែអំបិល មានចំនួន០១ទីតាំង គឺផ្សារស្រែអំបិល។

## ៣. កង្វះខាតក្នុងការរក្សាទុកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

តាមគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតម្រូវឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានរៀបចំរួច ទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិនៃទីចាត់ការហិរញ្ញវត្ថុខេត្ត ធ្វើជាសេនាធិការក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្ត និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង-ស្រុក ធ្វើជាសេនាធិការក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុង-ស្រុក។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកោះកុងបានដកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន០៤ប័ណ្ណ ពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដោយមិនដឹងបានរក្សាទុកនៅកន្លែងណាមួយនៅឡើយ ក្នុងនោះ ៖

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៩០៥០១០៦-១៩១៤ មានទំហំសរុប **៣ ០០៦ ៤១៥**ម² ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៩០២០១០១-០០០១ មានទំហំសរុប **៧៤៣ ៧៨៥**ម² ស្ថិតនៅភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៩០៧០៤០៣-០២៦៧ មានទំហំសរុប **១៨ ២៣៨**ម² ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៩០៧០៤០៣-០២៦៨ មានទំហំសរុប **៣៨ ៦៤៣**ម² ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង។

## ៤. ការមិនទាន់បានចែកដីសម្បទានសង្គមកិច្ច

ដីសម្បទានសង្គមកិច្ចអាចត្រូវបានផ្តល់ឱ្យដល់រូបវន្តបុគ្គល ឬក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ សម្រាប់គោលដៅសង្គមកិច្ច ដោយអនុលោមតាមគោលដៅណាមួយ ឬគោលដៅច្រើន ដូចជា ការផ្តល់ដីដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅសម្រាប់សាងសង់លំនៅឋាន ដែលមានទំហំ១ ២០០ម² (ទំហំធំបំផុត៣ ៦០០ម²) និងដីសម្រាប់កសិកម្មជាលក្ខណៈគ្រួសារដែលមានទំហំ០២ហិកតា (ទំហំធំបំផុត០៥ហិកតា) ព្រមទាំងការផ្តល់ដីដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានជាថ្មី និងគ្រួសារដែលរងគ្រោះ

ដោយគ្រោះធម្មជាតិគ្រួសារមាតុភូមិនិវត្តន៍ យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ក៏ដូចជាការជួយសម្រួលផ្តល់ដីដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ចដោយផ្តល់ដីឡូត៍ដល់កម្មករចំការធំៗ សម្រាប់សង់លំនៅឋាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ព្រមទាំងអភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (ជាសមាជិកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត) ទើបតែបានរៀបចំគម្រោងបែងចែកដីឡូត៍បានចំនួន៣៦៧ឡូត៍ ដែលមានទីតាំងនៅភូមិកោះកុងក្នុង និងភូមិព្រែកអង្គុញ ឃុំត្រពាំងរូង ស្រុកកោះកុង ជូនកងកម្លាំងប្រដាប់អាវុធ និងក្រុមគ្រួសារយុទ្ធជន។ បច្ចុប្បន្ននេះ រដ្ឋបាលខេត្តកោះកុងបានចុះបញ្ជីដីរដ្ឋសម្រាប់គោលដៅដីសម្បទានសង្គមកិច្ចចំនួន០៩ប័ណ្ណ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកថ្មបាំងចំនួន០២ប័ណ្ណ មានទំហំសរុប**៣ ៥៨៨ ៧០២**ម$^{២}$ ស្រុកកោះកុងចំនួន០៦ប័ណ្ណមានទំហំសរុប**១២ ៣៨១ ១៥២**ម$^{២}$ និងស្រុកបូទុមសាគរចំនួន០១ប័ណ្ណ មានទំហំសរុប**៦ ៩០៥ ៩៥៨**ម$^{២}$ ។

## ៥. កង្វះខាតក្នុងការថែរក្សា និងការការពារទ្រព្យសម្បត្តិរដ្ឋ

តាមគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតម្រូវឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដែលបានទទួលសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវមានកាតព្វកិច្ចថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍ ឬកែលម្អទ្រព្យសម្បត្តិរដ្ឋ ឱ្យកាន់តែល្អប្រសើរប្រកបដោយចីរភាព ដើម្បីធានាមិនឱ្យបាត់បង់ ឬខូចខាត ដោយត្រូវរក្សាទាំងបរិមាណ និងគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ទាំងរដ្ឋបាលខេត្តកោះកុង និងរដ្ឋបាលស្រុកចំនួន០៣ នៃខេត្តកោះកុង មិនអាចថែរក្សា និងការពារទ្រព្យសម្បត្តិ ដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ក្នុងនោះ៖

- រដ្ឋបាលខេត្តកោះកុង មិនអាចគ្រប់គ្រងនូវទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនចំនួន០១ទីតាំង ស្ថិតនៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ទំហំសរុប**៦ ៩០៥ ៩៥៨**ម$^{២}$
- រដ្ឋបាលស្រុកកោះកុងបានកត់ត្រាដីចំនួន០៣ទីតាំង មានទំហំសរុបចំនួន**២៧០ ០០០**ម$^{២}$
- រដ្ឋបាលស្រុកបូទុមសាគរបានកត់ត្រាដីចំនួន០១ទីតាំង មានទំហំសរុប**៣០ ០០០**ម$^{២}$
- រដ្ឋបាលស្រុកស្រែអំបិលចំនួន០៨ទីតាំង មានទំហំសរុប**១៩៦ ៦៦៤**ម$^{២}$ ។

កំហុសឆ្គងខាងលើនេះ បានកើតចេញពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កម្រិតរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង ដោយមានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកនៃខេត្តកោះកុង ព្រមទាំងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ជាតំណាងស្របច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រង ការថែរក្សា ការការពារ និងការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋទាំងឡាយដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ឱ្យបានគង់វង្ស ព្រមទាំងកត់ត្រាឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន តាមការណែនាំរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ហើយត្រូវធ្វើការចាត់ចែង និងប្រើប្រាស់នូវទ្រព្យសម្បត្តិរដ្ឋទាំងឡាយតាមមុខសញ្ញានីមួយៗ ទៅតាមក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន។

អាជ្ញាធរសវនកម្មជាតិសូមផ្តល់អនុសាសន៍ជូនរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុកនៃខេត្តកោះកុង ព្រមទាំងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដូចតទៅ៖

១. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គួរខិតខំបន្តចុះបញ្ជីដំបូងនៃទ្រព្យសម្បត្តិសាធារណៈឯកជនរបស់រដ្ឋ ដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើអនុប្បយោគជូនរដ្ឋបាលខេត្តកោះកុង និងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួនផ្ទាល់ ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន ហើយត្រូវបញ្ជូនវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានចុះបញ្ជី និងដីដែលកំពុងដំណើរការចុះបញ្ជី ព្រមទាំងដីមិនទាន់បានដំណើរការចុះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងអស់មកអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង ដើម្បីរក្សាទុក និងកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន។ លើសពីនេះទៀត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គួរខិតខំស្វែងរកនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានបាត់ចំនួន០៤ប័ណ្ណ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ត្រូវបំពេញបែបបទស្នើសុំទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង ដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុទុតិយតា។

២. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក គួររិះរកមធ្យោបាយឱ្យសមស្រប ក្នុងការទប់ស្កាត់ពីការទន្ទ្រានកាន់កាប់ដីរដ្ឋដែលបានចុះបញ្ជី និងមិនទាន់ចុះបញ្ជីពីសំណាក់ប្រជាពលរដ្ឋមួយចំនួន តាមវិធាន និងនីតិវិធីទន់ភ្លន់។ ក្នុងករណីចាំបាច់ គួរអនុវត្តវិធានតាមផ្លូវច្បាប់ចំពោះជនអនាធិបតេយ្យដែលបានទន្ទ្រានកាន់កាប់ដីរដ្ឋ។

៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង-ស្រុក គួររៀបចំផែនការនៃការបែងចែកដីសម្បទានសង្គមកិច្ច ទៅតាមមុខសញ្ញានៅតាមបណ្តារដ្ឋបាលក្រុង-ស្រុកនីមួយៗនៃខេត្តកោះកុង ឱ្យបានទាន់ពេលវេលា និងតាមមុខសញ្ញានៃតម្រូវការជាក់ស្តែង ដើម្បីទប់ស្កាត់ឱ្យបាននូវអធិករណ៍នានាដែលនៅតែបន្តកើតឡើង និងដើម្បីចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ប្រកបដោយបរិយាប័ន្នរវាងកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ និងគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាដែលកំណត់។

**មតិរបស់រដ្ឋបាលខេត្តកោះកុង**

រដ្ឋបាលខេត្តកោះកុង ក៏ដូចជារដ្ឋបាលក្រុង-ស្រុក ក្នុងនាមអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋផង និងក្នុងនាមគណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិផង សូមឯកភាពតាមលទ្ធផលសវនកម្ម និងសូមទទួលយកនូវអនុសាសន៍សវនកម្មដែលអាជ្ញាធរសវនកម្មជាតិបានផ្តល់ជូន ដើម្បីអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។